

សេវាកម្មទំនាក់ទំនងផ្ទាល់

បទដ្ឋានសុវត្ថិភាព សម្រាប់ MA

សេវាកម្មទំនាក់ទំនងផ្ទាល់គឺត្រូវបានរៀបចំឡើងតាម “ជំហានទី ២” ក្នុងដំណាក់កាលទី ២ នៃផែនការ បើកឡើងវិញ ។ នេះមានន័យថាសេវាកម្មទំនាក់ទំនងផ្ទាល់នឹងត្រូវបានពន្យារពេលចាប់ផ្តើមក្នុងដំណាក់កាលទី ២ ។

ហាងកាត់សក់បុរសនិងនារីដែលត្រូវបានអនុញ្ញាតឱ្យបើកដំណើរការក្នុងដំណាក់កាលទី ១ នៃផែនការបើកឡើងវិញនឹងក្លាយជាកម្មវត្ថុនៃបទដ្ឋានសុវត្ថិភាពនៅកន្លែងធ្វើការ ហើយសេវាកម្មទំនាក់ទំនងផ្ទាល់នឹងត្រូវបានអនុញ្ញាតឲ្យផ្តល់សេវាកម្ម ។

សេវាកម្មទំនាក់ទំនងផ្ទាល់គឺសំដៅទៅលើការផ្តល់សេវាកម្មផ្ទាល់ដែលរួបរាងកាយអ្នកផ្តល់សេវាកម្មស្ថិតនៅជិតគ្នាជាមួយនឹងអតិថិជនដោយរាប់បញ្ចូលទាំង៖

- **ក. សេវាកម្មបកធាម** រួមបញ្ចូលទាំងសេវាកម្មបាញ់ឡាស៊ែរ បកធាម សេវាកម្មបកធាមដោយក្រមួន បកធាមដោយប្រើខ្សែ និងសេវាកម្មដកធាមដោយអេឡិចត្រូនិក
- **ខ. ម៉ាស្សា ម៉ាស្សាខ្លួន ការចាក់ម្ជុលលើសសៃ ម៉ាស្សាដោយថាមពល និងការម៉ាស្សាដោយប្រើចលនាផ្សេងៗទៀត**
- **គ. សេវាកម្មថែទាំស្បែក** រួមបញ្ចូលទាំងការបកស្បែក បកមុខ ប្រើស៊េរ៉ូម ការចាក់ថ្នាំ Botox និងចាក់ថ្នាំឱ្យមុខស
- **ឃ. សេវាកម្មថែទាំក្រចក** ដោយរាប់បញ្ចូលទាំងការតុបតែងក្រចក
- **ង. សេវាកម្មថែទាំសក់** ដោយរាប់បញ្ចូលទាំងសេវាកម្មផ្លាស់ប្តូរសក់ សេវាកម្មបណ្តុះសក់
- **ច. ហាងតុបតែងមុខ**
- **ឆ. សេវាកម្មការតុបតែងមុខ**
- **ជ. គ្រូបណ្តុះបណ្តាលផ្ទាល់ខ្លួន** ប៉ើស្ថិនក្នុងដំណាក់កាលទី ២ សេវាកម្មបណ្តុះបណ្តាលផ្ទាល់ខ្លួនតាមផ្ទះ ត្រូវបានកម្រិតត្រឹមតែជាការបណ្តុះបណ្តាលធ្វើឡើងសម្រាប់ការណាត់ជួបជាមុនជាមួយអតិថិជនតែម្នាក់ប៉ុណ្ណោះ (ឬ ពីរនាក់ពីគ្រួសារតែមួយ) ដែលត្រូវបានអនុញ្ញាតនៅក្នុងទីតាំងនោះក្នុងពេលតែមួយ
- **ឈ. ហាងកែសម្ផស្សដោយគ្រែកាំរស្មី** ដោយរាប់បញ្ចូលទាំងអាជីវកម្ម

ភាពចាំបាច់ បទដ្ឋានសុវត្ថិភាព



គម្លាតសង្គម

រៀបចំកន្លែងធ្វើការដើម្បីឲ្យមានទីធ្លាទូលាយយ៉ាងតិច ៦ ហ្វីត ពីគ្នា

ដំឡើងសញ្ញាសម្គាល់ដែលអាចមើលឃើញ ដើម្បីលើកទឹកចិត្តអតិថិជនឱ្យរក្សាគម្លាតយ៉ាងតិច ៦ ហ្វីត ពីគ្នា

ការញ៉ាំអាហារនិងពេលសម្រាករបស់បុគ្គលិកត្រូវនៅដាច់ដោយឡែកពីគ្នា ហើយការសម្រាកត្រូវកំណត់ចំនួនមនុស្សអតិបរមានៅកន្លែងតែមួយ និងធានាឱ្យបានគម្លាតផ្នែករាងកាយយ៉ាងហោចណាស ៦ ហ្វីត

បិទឬកំណត់រចនាសម្ព័ន្ធកន្លែងធ្វើការរួមរបស់កម្មករនិងតំបន់ដែលមានដង់ស៊ីតេខ្ពស់ដែលជាកន្លែងកម្មករទំនងជាអាចប្រមូលផ្តុំគ្នាបាន (ឧទាហរណ៍..បន្ទប់សម្រាក កន្លែងបរិភោគអាហារ) អនុញ្ញាតឱ្យមានគម្លាតផ្នែករាងកាយពីគ្នាចំនួន ៦ ហ្វីត

ការបិទបាំងមុខគឺ តម្រូវឲ្យមានសម្រាប់កម្មករនិងភ្ញៀវទាំងអស់លើកលែងតែបុគ្គលមិនអាចពាក់ម៉ាសមុខដោយសារស្ថានភាពសុខភាព ឬពិការភាព ។

តំរូវអោយកម្មករពាក់ស្រោមដៃ អាវវែង ឬ អាវជាយ និងវ៉ែនតា វ៉ែនតាសុវត្ថិភាព ឬ វ៉ែនតាងូតទឹក

ដំឡើងរនាំងរវាងកន្លែងការងារនីមួយៗដែលអាចធ្វើទៅបានដោយរនាំងទាំងអស់ត្រូវមានកម្ពស់យ៉ាងតិច ៦ ហ្វីត

គ្មានអតិថិជនណាម្នាក់ដែលត្រូវបានអមដំណើរក្នុងអំឡុងពេលនៃសេវាកុម្មផ្ទាល់ខ្លួនទេលើកលែងតែមនុស្សដែលបម្រើការជាអ្នកថែទាំ ឬអ្នកណាព្យាបាល ។ ភ្ញៀវទាំងអស់គួរតែសង្កេតមើលរាល់តម្រូវការផ្សេងទៀតរបស់អតិថិជនដទៃ រួមទាំងការពាក់បាំងមុខ និងរក្សាចម្ងាយ ៦ ហ្វីត ពីមនុស្សផ្សេងទៀតដែលមានវត្តមាន

ការអនុវត្តដ៏ប្រសើរដែលត្រូវបានណែនាំ

រៀបចំកន្លែងធ្វើការឱ្យមានបរិយាកាសប្រសើរឡើងតាមដែលអាចធ្វើទៅបាន (ឧទាហរណ៍..បើកទ្វារ និងបង្អួច)

វិធីសាស្ត្រទូទាត់ដោយគ្មានការទាក់ទងត្រូវបានលើកទឹកចិត្ត

លើកទឹកចិត្តចំពោះការមកទទួលយកទំនិញនៅខាងក្រៅ ឬ ការចែកចាយទំនិញលក់រាយណាមួយដែលអតិថិជនបានទិញត្រូវធ្វើឡើងនៅនឹងកន្លែងដោយផ្តល់នូវសេវាណាតជួបជាមុននឹងធ្វើតាមការណែនាំនៃអាជីវកម្មលក់រាយសម្រាប់អតិថិជនដែលស្វែងរកការទិញរាយ ឬ បន្ថែមលើសេវាកម្មផ្ទាល់ខ្លួន



វិធានការអនាម័យ

ធានាថាការចូលទៅកន្លែងលាងដៃត្រូវមានសាប៊ូ និងទឹកទុយូនិង អនុញ្ញាតឱ្យមានពេលវេលាសម្រាកគ្រប់គ្រាន់សម្រាប់កម្មករលាងដៃឱ្យបានញឹកញាប់ ។ ទឹកលាងដៃដែលមានជាតិអាល់កុលយ៉ាងតិច ៦០% អាចនឹងត្រូវបានប្រើជំនួស

ផ្តត់ផ្គង់ផលិតផលសម្អាតឱ្យបានគ្រប់គ្រាន់ទៅកម្មករនៅតាមទីតាំងផ្សេងៗនៃកន្លែងធ្វើការ (ឧទាហរណ៍.. ក្រដាសអនាម័យ ក្រដាសជូតសម្លាប់មេរោគ ទឹកកម្ចាត់មេរោគ)

តម្រូវឱ្យមានការផ្លាស់ប្តូរស្រោមដៃ និងលាងដៃមុននិងក្រោយពេលផ្តល់សេវាកម្មដល់អតិថិជនម្នាក់ៗ

គ្មានការអនុញ្ញាតឱ្យចែករំលែកឧបករណ៍ និងការផ្តត់ផ្គង់រវាងកម្មករនីមួយៗទេ (ឧទាហរណ៍...ដង្កៀបកៀបសក់ ឧបករណ៍ចោះក្រវិល ច្រាស ម្ជុលចាក់ថ្នាំ ។ ល ។) ។ ឧបករណ៍ទាំងអស់ត្រូវតែសម្អាតរវាងអតិថិជនម្នាក់ៗ

កម្មករទាំងអស់គួរផ្លាស់ប្តូរសម្លៀកបំពាក់វែង ឬ អាវជាយ រវាងការបម្រើសេវាកម្មសម្រាប់អតិថិជននីមួយៗ ពិចារណាការប្រើមួកនិងសម្លៀកបំពាក់វែងតែម្តងបោះចោល ។ មួក កន្សែង អាវជាយ ដែលអាចប្រែប្រាសឡើងវិញគួរតែអ៊ុតនៅចន្លោះពេលដែលប្រែប្រាសម្តងៗ

ដាក់ស្លាកសញ្ញាដែលអាចមើលឃើញនៅនឹងកន្លែងធ្វើការដើម្បីរំលឹកដល់កម្មករនិងអតិថិជនអំពីវិធានការសុវត្ថិភាពនិងអនាម័យ

ព័ត៌មានលម្អិតបន្ថែមស្តីពីវិធានការជាក់លាក់អាចរកបាននៅhttps://www.mass.gov/info-details/reopening-massachusetts



សេវាកម្មទំនាក់ទំនងផ្ទាល់

បទដ្ឋានសុវត្ថិភាព សម្រាប់ MA

ភាពចាំបាច់ បទដ្ឋានសុវត្ថិភាព

ការរៀបចំបុគ្គលិកនិង ប្រតិបត្តិការ

ផ្តល់ការបណ្តុះបណ្តាលដល់កម្មករអំពីព័ត៌មានសុវត្ថិភាពនាពេលបច្ចុប្បន្ន និងការប្រុងប្រយ័ត្នរួមមានអនាម័យ និងវិធានការសុវត្ថិភាពផ្សេងៗទៀតក្នុងការកាត់បន្ថយនូវការចម្លងមេរោគដោយរាប់បញ្ចូលទាំង៖

- គម្លាតសង្គម ការលាងដៃ ការប្រើម៉ាស់គ្របមុខឱ្យបានត្រឹមត្រូវ
- ត្រូវត្រួតពិនិត្យដោយខ្លួនឯងនៅផ្ទះរួមទាំងការត្រួតពិនិត្យសីតុណ្ហភាព ឬ រោគសញ្ញាផ្សេងៗ
- ត្រូវបញ្ជាក់បន្ថែមថាចំពោះកម្មកររដែលឈឺមិនត្រូវមកធ្វើការងារឡើយ
- ប្រសិនបើរោគសញ្ញាកាន់តែធ្ងន់ធ្ងរត្រូវស្វែងរកការព្យាបាល
- លក្ខខណ្ឌសុខភាពមូលដ្ឋានដែលអាចធ្វើឱ្យបុគ្គលងាយនឹងឆ្លង និងទទួលរងពីករណីធ្ងន់ធ្ងរនៃវីរុស
កែតម្រូវម៉ោងការងារ និងការផ្លាស់ប្តូរវេនការងារ (ក្រុមការងារត្រូវធ្វើការដែលមានកាលវិភាគផ្សេងៗគ្នា ឬ ការមកដល់ / ចាកចេញដោយឯកឯង)ដើម្បីកាត់បន្ថយការទាក់ទងគ្នារវាងកម្មករនិងកាត់បន្ថយការកកស្ទះ
តម្រូវឲ្យអតិថិជនធ្វើការណាត់ជួបទុកជាមុន មុននឹងទទួលបានសេវាកម្ម
បិទកន្លែងរង់ចាំនិងស្នើឱ្យអតិថិជនរង់ចាំខាងក្រៅ ឬ ក្នុងឡានរហូតដល់មានការណាត់ជួបត្រូវបានអនុវត្ត
រក្សាកំណត់ហេតុកម្មកររនិងអតិថិជនដើម្បីងាយស្រួលក្នុងការធ្វើទំនាក់ទំនង (ឈ្មោះ កាលបរិច្ឆេទ ពេលវេលា ព័ត៌មានទំនាក់ទំនង)
ដកសម្ភារដែលមិនចាំបាច់ចេញ (ទស្សនាវដ្តី ទឹក ឬ កាហ្វេ ដែលត្រៀមសម្រាប់អតិថិជន បន្ទប់ខោអាវ ។ ល ។)
កម្មកររដែលចាប់ផ្តើមឈឺ មិនត្រូវមានវត្តមាននៅកន្លែងធ្វើការទេ

ប្រសិនបើនិយោជកត្រូវបានគេជូនដំណឹងអំពីករណីវិជ្ជមាននៅកន្លែងធ្វើការ និយោជកត្រូវជូនដំណឹងទៅក្រុមប្រឹក្សាសុខភាពមូលដ្ឋាន (LBOH) ក្នុងទីក្រុង ឬ ប្រជុំជនដែលស្ថិតនៅនឹងកន្លែងធ្វើការផ្ទាល់ និងធ្វើការជាមួយ LBOH តាមការស្នើ ដើម្បីណែនាំកម្មករឱ្យនៅឆ្ងាយពីគេ និងឃុំខ្លួនឯង ។ ការធ្វើតេស្តលើកម្មករផ្សេងទៀតអាចត្រូវបាន ផ្តល់ជាមតិយោបល់ដែលស្របទៅនឹងការណែនាំនិង / ឬ តាមសំណើរបស់ LBOH

ជូនដំណឹងដល់កម្មករ និងអតិថិជននូវព័ត៌មានសុខភាពសំខាន់ៗ និងវិធានការពាក់ព័ន្ធនឹងសុវត្ថិភាពដែលមានចែងក្នុងបទដ្ឋានសុវត្ថិភាពចាំបាច់សម្រាប់កន្លែងការងាររបស់សហគមន៍

ការអនុវត្តដ៏ប្រសើរដែលត្រូវបានណែនាំ

កម្មកររដែលងាយរងគ្រោះចំពោះកូវីដ-១៩ យោងតាមមជ្ឈមណ្ឌលត្រួតពិនិត្យជម្ងឺ គួរត្រូវបានលើកទឹកចិត្តឱ្យស្នាក់នៅផ្ទះ ឬបែងចែកការកិច្ចឡើងវិញដើម្បីកាត់បន្ថយការទាក់ទងជាមួយកម្មករនិងអតិថិជនផ្សេងទៀត
លើកទឹកចិត្តកម្មកររដែលមានរោគសញ្ញាឬសង្ស័យមានទំនាក់ទំនងជិតស្និទ្ធនឹងអ្នកមានរោគសញ្ញាកូវីដ-១៩ ត្រូវរាយការណ៍ទៅនិយោជក
លើកទឹកចិត្តកម្មកររដែលធ្វើតេស្តវិជ្ជមានសំរាប់កូវីដ-១៩ ដើម្បីរាយការណ៍ទៅការិយាល័យនិយោជកក្នុងគោលបំណងសម្អាត / កម្ចាត់មេរោគ និងតាមដានរាល់ទំនាក់ទំនង។

ការសម្អាតនិង ការកម្ចាត់មេរោគ

សម្អាតផ្ទៃដែលប៉ះញឹកញាប់ជាធម្មតានៅក្នុងបន្ទប់ទឹក (ឧទាហរណ៍... ចានបង្គន់ កៅអី ដៃទ្វារ គន្លឹះទ្វារ កន្លែងលាងដៃ ប្រអប់ដាក់ក្រដាសជូតប្រអប់ដាក់សាប៊ូ) ឱ្យបានញឹកញាប់និងអនុលោមតាមគោលការណ៍ណែនាំរបស់ CDC

អនុវត្តការលាងសម្អាតញឹកញាប់និងការកម្ចាត់មេរោគនៅនឹងកន្លែង (យ៉ាងហោចណាស់រៀងរាល់ថ្ងៃ និង ញឹកញាប់ ប្រសិនបើអាច)

រក្សាកំណត់ហេតុសម្អាតដែលរួមមានកាលបរិច្ឆេទ ពេលវេលានិងទំហំនៃការសម្អាត

ធ្វើការបោសសម្អាតជាញឹកញាប់នូវតំបន់ឆ្លងរោគដែលធ្ងន់ធ្ងរ និងផ្ទៃដែលប៉ះពាល់ញឹកញាប់ (ឧទាហរណ៍... ដៃទ្វារ បង្គាន់ដៃជណ្តើរ ខ្នើយកល់ក្បាល ដៃកៅអី ។ ល ។)

ក្នុងករណីកម្មករ អតិថិជន ឬ អ្នកលក់ដូរណាម្នាក់មានករណីវិជ្ជមាន សូមបិទកន្លែងនិងរង់ចាំ ២៤ ម៉ោង មុនសម្អាត និងកម្ចាត់មេរោគនៅកន្លែងធ្វើការស្របតាមការណែនាំរបស់ CDC នាពេលបច្ចុប្បន្ន

ធ្វើឱ្យខូចឬជំនួសឧបករណ៍អនុវត្តនិងផ្ទៃរវាងអ្នកតិថិជន (ឧទាហរណ៍...តុ កូនចានគោម កៅអីនិងខ្នើយកល់ក្បាល វ៉ែកជ័រ ដង្កៀបកៀបសក់ ឧបករណ៍ចោះក្រវិល ឧបករណ៍តុបតែងខ្លួនដទៃទៀត)

ប្រសិនបើឧបករណ៍ទាំងនោះមិនត្រូវបានកម្ចាត់មេរោគទេ (ឧទាហរណ៍...ឧបក្រណ៍ដែលមានមុខងារច្រើន ដូចជា ឈុតឧបករណ៍ធ្វើក្រចក ឧបករណ៍ដុសខាត ឧបករណ៍ខួង ។ ល ។) ត្រូវតែបោះចោលពួកវាបន្ទាប់ពីប្រើរួច

ការកម្ចាត់មេរោគលើកៅអី តុ និង / ឬ កន្លែងធ្វើការរវាងអតិថិជននីមួយៗ ឬ ប្រើគម្របផ្លាស្ទិចដែលអាចចោលបានសម្រាប់អតិថិជនម្នាក់ៗ ដោយសង្កេតមើលពេលវេលាទំនាក់ទំនងនៅលើផ្លាកសញ្ញាសម្រាប់ ដើម្បីធ្វើការកម្ចាត់មេរោគឱ្យបានត្រឹមត្រូវ ។

បោកក្រណាត់ទាំងអស់ កន្សែងជូតនិងសម្លៀកបំពាក់វែងជាមួយទឹកសាប៊ូ ហើយហាលឱ្យស្ងួតជាប្រចាំនិងរវាងការប្រើប្រាស់នីមួយៗ

ព័ត៌មានលម្អិតបន្ថែមស្តីពីវិធានការជាក់លាក់អាចរកបាននៅhttps://www.mass.gov/info-details/reopening-massachusetts